# ៦.រឿង ប្រាសាទភ្នំជីសូរ

ភ្នំជីសូរ ជាឈ្មោះទីកន្លែងមួយ ដែលគេស្គាល់ច្រើន ក្នុងមជ្ឈដ្ឋានអ្នកចូលចិត្តធ្វើដំណើរកម្សាន្តតាមទីជិត ឬឆ្ងាយ ព្រោះជាទីដំណែលបុរាណ ហើយជារមណីយដ្ឋានដែលទើបនឹងរៀបចំថ្មីៗ ក្នុងប្រទេសកម្ពុជាយើង ។ ការល្បីរន្ទឺនាមដូច្នេះ ជាហេតុនាំឲ្យអ្នកផងចង់ដឹងអំពីភាពរាង ទីតាំង និង ប្រវត្តិដើមរបស់កន្លែងនេះ ឲ្យរឹងរឹតបានច្បាស់លាស់ឡើង ព្រោះបណ្តាអ្នកដែលពុំទាន់បានឃើញ ក៏មានគំនិតឆ្ងល់ ចង់ឃើញ ចង់ដឹងទាំងស្រុង, ចំណែកអ្នកដែលធ្លាប់បានស្គាល់ហើយ ក៏រមែងនៅមានឆ្ងល់ពីប្រវត្តិ ដើមកំណើតទីនេះ ជាមិនខានដែរ ។

អាស្រ័យហេតុនេះហើយ បានជាក្រុមជំនុំទំនៀមទម្លាប់ខ្មែរ មានភារៈធ្វើការស្រាវជ្រាវ រកហេតុផលច្បាស់លាស់ យកមកអធិប្បាយបញ្ជាក់ជូនក្នុងគ្រានេះ ដោយប្រមូលឯកសារ ដែលសមាជិកឆ្លើយឆ្លងនៅខេត្តក្រៅ សរសេរឲ្យព័ត៌មានមក និង ដោយការចាត់ឲ្យសមាជិក ចេញទៅពិនិត្យសង្កេតផ្ទាល់ដល់ទីកន្លែងព្រមទាំងសាកសួរអ្នកស្រុក ដែលនៅជិតខាងទីនោះទៀតផង ។

ភ្នំជីសូរស្ថិតនៅក្នុងឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ គឺនៅជាប់នឹងផ្លូវជាតិ ដែលបែកចេញពីផ្លូវជាតិលេខ ២ (ភ្នំពេញ-តាកែវ) កាត់តម្រង់ទៅឯផ្សារព្រៃល្វា ស្រុកព្រៃកប្បាស ។ ផ្លូវថ្នល់ត្រង់ជើងភ្នំនេះ ជ្រុងខាងជើងមានបែកជា ៣ គឺមួយ ចូលពីវត្តប្រាសាទនាងខ្មៅ, មួយបែកពីផ្លូវជាតិ កាត់មកតាមផ្សារបត់រកា (សាលាស្រុកសំរោង) និង មួយទៀតមកពីផ្សារព្រៃល្វា (សាលាស្រុកព្រៃកប្បាស) មកប្រសព្វគ្នាត្រង់កន្លែងនេះ ។ ដូច្នេះ អ្នកធ្វើដំណើរទៅពីភ្នំពេញ ដោយរថយន្តផ្ទាល់ខ្លួន អាចបត់ចូលតាមផ្លូវបែក ត្រង់វត្តប្រាសាទនាងខ្មៅក៏បាន ឬ ចាំទៅបត់តាមផ្លូវបំបែកចូលផ្លូវបត់រកាក៏បាន ។

សព្វថ្ងៃ នៅលើកំពូលភ្នំនេះ មានប្រាសាទបុរាណមួយតូចល្មម ប៉ុន្តែមានរបៀបរៀបរយប្រកបដោយផែនទីសមរម្យនៅឡើយ ។ ប្រាសាទនេះហើយ ដែលអ្នកផងនិយមហៅថា "ប្រាសាទភ្នំជីសូរ" ហើយដែលយើងអធិប្បាយពីខាងដើមថា អ្នកផងគេនិយមទៅទស្សនាជាញឹកញាប់ ។ តាមពិត រូបរាងប្រាសាទនេះ ពុំមានភាពស្កុកស្កម្ភ ដូចប្រាសាទអង្គរ ឬ ប្រាសាទដទៃទៀត នៅចំណោមអង្គរឡើយ, គេប្រទះឃើញតែកំពែងព័ទ្ធជុំវិញប៉ុណ្ណោះ ដែលនៅគង់ទ្រង់ ។ កំពែងនេះ ធ្វើពីថ្មភក់ ឬ ថ្មបាយក្រៀម តម្រៀបគ្នាជាពីរតម្រួតក្នុងក្រៅ ឃ្លាតពីគ្នាប្រមាណជា ២ ម៉ែត្រ ហើយខាងលើ មានតម្រៀបថ្មដូចគ្នានេះ ធ្វើជាដំបូលប្រក់ពីលើ អាចឲ្យមនុស្សជ្រកនៅក្នុងនេះបានយ៉ាងស្រួល ។ ជ្រុងទាំងបួននេះ មានទ្វារធំៗ នៅគ្រប់ទាំងបួនទិស ដោយមានថ្មឆ្លាក់ជាក្បាច់គ្របកឈូក បន្តុបគ្នាជាកំពូលប្រាង្គ ដ៏មានក្បាច់ផ្តែ និង ក្បាច់ស៊ុមយ៉ាងស្រស់ គួរជាទីទស្សនាណាស់ផង ។ សងខាងទ្វារសំខាន់នេះ មានទ្វារតូចៗ ពីរ ដែលមានចន្លោះ ល្មមតែចុះខ្លួនមនុស្សម្នាក់ចេញចូលបាន ។ រូបចម្លាក់សំខាន់ជាងគេ នៅក្នុងផ្តែនៃខ្លោងទ្វារទាំងនោះ មានរូបព្រះឥសូរ គង់លើអាសនៈក៏មានស្រីស្នំគាល់ហ្មៅ និង ពពួកសត្វលោក ឱនក្បាលគោរព ដង្ហូវដង្ហៃខ្លាចព្រះបារមី ។

សព្វថ្ងៃ កំពែងជុំវិញនេះ ទៅជាកំពែងព្រះវិហារព្រះពុទ្ធសាសនា ដែលទើបតែនឹងសង់ឡើងនៅគ្រាបច្ចុប្បន្ន
ទៅវិញ គ្រាន់តែនៅសល់បណ្ណាល័យបុរាណ ជាថ្មបាក់បែកនៅសល់ សងខាងវិហារប៉ុណ្ណោះ ។

ដូច្នេះ មុននឹងជម្រាបទ្រង់ទ្រាយច្បាស់លាស់ ហាក់ដូចជាជួយបង្ហាញទីកន្លែងហ្វូរហែ ដល់លោកអ្នកអាន
យើងសូមជម្រាបអំពីប្រវត្តិពង្សាវតារនៃបុរាណដ្ឋាននេះ ជាមុនសិន ។ ប្រវត្តិនេះឯង មានពីរស្ថាន គឺមួយ
តាមការស្រាវជ្រាវ ដោយយកសិលាចារឹកធ្វើជាមូលដ្ឋាន និងមួយបែបទៀត ផ្អែកទៅលើរឿងព្រេងនិទាន
ដែលអ្នកស្រុកនិយាយរត់មាត់តៗ គ្នា ជាច្រើនតំណមនុស្សមកហើយ ។

សិលាចារឹក ដែលអ្នកស្រាវជ្រាវ បានរកឃើញនៅលើភ្នំជីសូរ ទាំងអស់មាន ៤ គឺ បីផ្ទាំង ជាគោលដោយខ្លួ
នៗ ពីគ្នា និងមួយផ្ទាំងទៀត ចារជាប់នឹងស៊ុមទ្វារ (Piédroit) ។ សេចក្ដីក្នុងសិលាចារឹកទាំងអស់នេះមានចុះ
នាមព្រះមហាក្សត្រ ៣ ព្រះអង្គ គឺព្រះបាទសូរ្យវរ្ម័នទី ១ (គ. ស. ១០០២-១០៤៩) ព្រះបាទធរិណាន្ទ្រវរ្ម័នទី ១
(គ. ស. ១១០៧-១១១៣) ព្រះបាទសុរ្យវរ្ម័នទី ២ (គ. ស. ១១១៣- ១១៤៥) ដែលជាហេតុនាំឲ្យយើង ចាប់
សេចក្ដីបានថា ព្រះរាជាទាំង ៣ ព្រះអង្គនេះ មានការទាក់ទងក្នុងដំណើរសាងបុរាណវត្ថុនេះ ជាប្រាកដ ។
ដូច្នេះ យើងស្រង់យកន័យជាដំណើរសាងទីកន្លែងនេះ មកចុះក្នុងសេចក្ដីស្រាវជ្រាវបាន ដោយសង្ខេបថា ៖

ចាប់ផ្ដើមឡើង, សិលាចារឹករបស់បណ្ឌិតសិវាចារ្យ សរសេរថា កាលនោះ ៩៣៩ ស័ក (គ. ស. ១០១៧) ក្នុង
រជ្ជកាលព្រះបាទសុរ្យវរ្ម័នទី ១, លោកបណ្ឌិតសិវាចារ្យ បានចូលបព្វជ្ជាក្នុងសាសនាព្រាហ្មណ៍ ស្ថិតក្នុងទី
អាស្រមបទមួយកន្លែងឈ្មោះ យោគេន្ទ្រាល័យ ដែលពពួកអ្នកមានសទ្ធាជំនាន់នោះ បានរួបរួមគ្នាកសាង
ឡើង នៅលើកំពូលភ្នំ (គឺជីសូរនេះឯង) ។ បន្ទាប់មក មានមន្ត្រីជាន់ខ្ពស់ម្នាក់នាម គម្តែងអញ ស្រីវីរិន្ទ្រ ដែល
ជាអ្នកឧបត្ថម្ភអាស្រមបទ "យោគេន្ទ្រាល័យ" និងជាឧបដ្ឋាករបស់បណ្ឌិតសិវាចារ្យផង លោកបានផ្ដើមគំនិត
រើតាក់តែងទីអាស្រមនេះ ឲ្យបានធំថ្កុំថ្កើងរុងរឿងទៀត ។ កិច្ចការដ៏ធំនេះ នឹងធ្វើទៅបាន លុះណាតែមាន
មធ្យោបាយគ្រប់គ្រាន់ ម្ល៉ោះហើយបានជាសិវាចារ្យ និង ស្រីវរិន្ទ្រ បានមូលមតិគ្នាធ្វើជាគម្រោងការមួយ ដាក់
ថ្វាយព្រះមហាក្សត្រទ្រង់ពិនិត្យ ដើម្បីសុំព្រះរាជានុញ្ញាត និង សុំព្រះរាជូបត្ថម្ភក៏ផង ។ កាលនោះ ព្រះបាទ
សុរ្យវរ្ម័នទី ១ ព្រះអង្គក៏ទ្រង់មេត្តាប្រោស តាមការស្នើនេះ ដោយបានទាំងប្រោសប្រទាន នូវវត្ថុមានតម្លៃ
សម្រាប់ជាការចំណាយក្នុងកិច្ចស្ថាបនានេះទៀត ។ មិនតែប៉ុណ្ណោះ ទ្រង់ប្រោសប្រទាននូវដីត្រង់តំបន់ដែល
ហៅថា យោគេន្ទ្រាល័យ និង ដីស្រុកភូមិមួយ ជាប់នឹងទីនេះ ដែលមានឈ្មោះថា "យោគេន្ទ្របុរៈ" ដល់ការ
ស្ថាបនានេះទៀត ។ ចាប់តាំងពីនោះមក បណ្ឌិតសិវាចារ្យ និង គម្តែងអញ ស្រីវរិន្ទ្រ នាំគ្នាចាត់ចែងស្ថាបនា
ទៅនេះ ឲ្យកើតឡើងជាតួប្រាសាទស្តុកស្តម្ភ ហើយក៏សុំប្រោសព្រះរាជទាន នូវនាមទីសក្ការសង់ថ្មី នៅលើ
ភ្នំនេះឲ្យហៅថា "សុរ្យបវ៌ត" ដែលបានន័យថា ភ្នំនៃព្រះបាទសុរ្យ" ។

កិច្ចការស្ថាបនានេះ ពុំមែនធ្វើហើយភ្លាមៗ ទេ, ហេតុនេះហើយបានជា ផុតពីរាជ្យ នៃព្រះបាទសុរ្យវរ្ម័នទី ១
ទៅ ក៏នៅតែបន្តកិច្ចការនេះតទៅ ក្នុងរាជ្យព្រះបាទធរណិន្ទ្រវរ្ម័នទៀត រហូតដល់រជ្ជកាលព្រះបាទសុរ្យវរ្ម័នទី
២ ទើបបានហើយស្រេច, ព្រះបាទសុរ្យវរ្ម័ន ទ្រង់យាងធ្វើជាព្រះរាជាធិបតី ក្នុងពិធីសម្ពោធបូជនីយដ្ឋាននេះ

ជាស្រេច ។ ដោយមានដំណើរដូច្នេះ ទើបសិលាចារឹកទាំងឡាយនៅលើភ្នំជីសូរ មានចែងអំពីព្រះនាមព្រះរាជាទាំង ៣ អង្គនេះ ។ កាលបើបានជាបូជនីយដ្ឋានស្តុកស្តម្ភហើយ ពពួកព្រាហ្មណ៍ ដែលទទួលភារៈក្នុងកិច្ចការស្ថាបនានេះ បន្តមកពី គម្តែងអញស្រីវិរិន្ទ្រ នោះមក ក៏កសាងជាបដិមាករសំខាន់ៗ តម្កល់នៅក្នុងទីនេះ ធ្វើជាទីសក្ការបូជា សម្រាប់អ្នកផងទូទៅ ។ បដិមាករសំខាន់ជាងគេ ថ្វាយនាមថា "វ្រះធ្វជ" ដែលជាតំណាងព្រះឥសូរ ហើយមានព្រះនាមមួយទៀត ដែលនិយាយក្នុងសិលាចារឹកជាញឹកញាប់ ហៅថា "គម្តែងជគត ស្រី សុព្រវន្នែ ទេវៈ" ។

សេចក្តីរៀបរាប់មកទាំងនេះ បញ្ជាក់តាមន័យក្នុងសិលាចារឹកទាំងប៉ុន្មានផ្ទាំង ដែលយើងចង្អុលបង្ហាញមកហើយខាងលើ ។ បន្តទៅទៀតនេះ យើងងាកបែរទៅលើកយករឿងព្រេង តាមអ្នកស្រុកចាំតៗ គ្នា មកអធិប្បាយម្តង, ព្រោះជាធម្មតា អ្នកស្រុកដែលនៅតាមទីកន្លែងក្បែរៗ នោះ រមែងមានចាំរឿងរ៉ាវតាមស្រុកតាមភូមិរបស់ខ្លួន រៀងៗ ខ្លួន ហើយរឿងទាំងនោះ ជួនកាល ក៏មានសារៈ គួរយកជាការបានខ្លះដែ ។

រឿងព្រេងនោះ ដំណាលថា ៖ កាលនោះ មានក្សត្រមួយព្រះអង្គ ព្រះនាមសុរិយា-ទេវេស សោយរាជ្យជាអង្វែងមកហើយ បានកសាងព្រះរាជនិវេសន៍នៅក្បែរជើងភ្នំមួយ (ភ្នំជីសូរសព្វថ្ងៃ) ដែលមានបឹងធំមួយទៀតហៅថា "ទន្លេឱម" នៅជាប់ពីខាងកើត ។ រាជនិវេសន៍នេះ ស្ថិតនៅកណ្តាលព្រៃមួយ ហៅថា "ព្រៃសែនភូវាំង" ក្រោយដែលសាងព្រះរាជនិវេសន៍រួចហើយ ព្រះរាជាទ្រង់ប្រារព្ធធ្វើពិធីចម្រើនព្រះគេសព្រះរាជឱរសរបស់ព្រះអង្គ ។ ព្រះរាជពិធីយ៉ាងឧឡារិក ក៏ផ្តើមឡើង ដោយមានពពួកព្រាហ្មណ៍ព្រឹទ្ធកវី ព្រឹទ្ធាចារ្យ ចូលថ្វាយសព្ទសាធុការពរ ចំពោះព្រះរាជឱរស បន្តបន្ទាប់គ្នា ។ ពេលនោះ មានព្រាហ្មណ៍ព្រឹទ្ធាចារ្យម្នាក់ ជាអធិបតីក្នុងពិធីនេះ បានចូលទៅថ្វាយព្រះពរក្រោយគេ មានសេចក្តី ៣ ប្រការ ប្លែកពីគេថា ៖ - សូមឲ្យមានកម្លាំងដូចស្រមោច - សូមឲ្យមានឫទ្ធិដូចខ្មោច - សូមឲ្យមានចិត្តមុតដូចមនុស្សស្រី

ក្រោយដែលទ្រង់ព្រះសណ្តាប់ឃ្លានេះចប់ ព្រះរាជាទ្រង់ក្រោធនឹងព្រាហ្មណ៍ព្រឹទ្ធាចារ្យមួយរំពេច, ប៉ុន្តែព្រាហ្មណ៍ សុំព្រះរាជានុញ្ញាត ធ្វើជាពិសោធយកជាបន្ទាល់ ថ្វាយព្រះអង្គទ្រង់យល់សិន ។ ព្រះមហាក្សត្រទ្រង់ប្រោសប្រទានតាមសេចក្តីសុំ ។

ដំបូង ត្រង់ពរថា "ឲ្យមានកម្លាំងដូចស្រមោច" ព្រាហ្មណ៍បង្គាប់ឲ្យធ្វើរូបដែកមួយ ប៉ុនខ្លួនមនុស្សម្នាក់ ហើយហៅមនុស្សម្នាក់ ឲ្យមកលើករូបដែកនេះល្បងមើល តែលើកមិនរួចសោះ ។ រួចព្រាហ្មណ៍ឲ្យយកម្ទូលមួយប៉ុនខ្លួនស្រមោច មកកាត់យកប្រវែងប៉ុនស្រមោច, ប្រឡាក់ទឹកឃ្មុំ ហើយយកទៅដាក់ឲ្យស្រមោចរោម, ពេលនោះ ស្រមោចមួយក៏ពាំកំណាត់ម្ទូលនោះបាត់ទៅ ។ ព្រាហ្មណ៍ ក្រាបបង្គំទូលព្រះមហាក្សត្រថា "ក្រាបទូល នេះហើយ ដែលថា កម្លាំងដូចស្រមោច" ។

ពរ ទី ២ ដែលថា "មានឫទ្ធិដូចខ្មោច" ព្រាហ្មណ៍ ឲ្យគេយកខ្មោចស្លាប់តៃហោង ៧ យ៉ាង គឺ ស្លាប់ដោយសម្រាលកូន ១, ដោយពស់ចឹក ១, ដោយក្រពើវែ ១, ដោយរន្ទះបាញ់ ១, ដោយគេលបកាប់ ១, ដោយលង់ទឹក ១, ដោយចងក ១, ហើយឲ្យយកខ្មោចទាំង ៧ នេះ ទៅកប់នៅឆ្ងាយពីភូមិស្រុក រួចហើយឲ្យយកផ្តិល

ប្រាក់ល្អៗ ទៅកប់នៅចំចន្លោះក្បាលខ្មោចនេះ ។ មិនតែប៉ុណ្ណោះឲ្យយកពែរួត, ពែហ៊ុម, ពៃជើងត្រុំ, ពែច្រមុះជ្រូក ជាដើម ទៅតម្រៀបនៅលើកំណប់ក្បាលខ្មោចនេះ ដោយមានដាក់បាយស បាយក្រហម ក្បាលជ្រូក មានឆ្កាងនៅត្រង់នោះផង, លុះដល់ពេលយប់ស្ងាត់ ព្រាហ្មណ៍ក៏ប្រើពួកអមាត្យណាម្នាក់ដែលចង់បានផ្តិលប្រាក់ ដែលកប់នោះ ឲ្យទៅជីកយកចុះ ។ ពេលនោះ គ្មាននរណាម្នាក់ ហ៊ានទៅយកផ្តិលប្រាក់នោះសោះ ។ ត្រង់នេះ ព្រាហ្មណ៍ ក្រាបទូលព្រះរាជាថា "នេះហើយ ដែលហៅថា ៖ មានឫទ្ធិដូចខ្មោច" ។

ចំណែកពរទី ៣ ដែលថា "មានចិត្តមុតដូចមនុស្សស្រី" នោះ, ព្រាហ្មណ៍ព្រឹទ្ធាចារ្យ បានធ្វើការពិសោធន៍វែងឆ្ងាយ ដូចតទៅនេះ ។ ដំបូងហៅបុរសកម្សត់ម្នាក់ មកនិយាយថា ៖ មើល៍ ! សព្វថ្ងៃនេះ អ្នកឯងកម្សត់តោកយ៉ាក, បើខ្ញុំបង្គាប់ឲ្យអ្នកសម្លាប់ប្រពន្ធអ្នកឯងចោល, ក្នុងរយៈបីថ្ងៃទៀត ខ្ញុំនឹងតាំងឲ្យអ្នកធ្វើជាមន្ត្រីធំ តើសុខចិត្តឬទេ ? ។ បុរសសញ្ជឹងគិតមួយសន្ទុះ ក៏ងើបឡើងឆ្លើយថា "ខ្ញុំមិនអាចធ្វើបានទេលោក ! ព្រោះភរិយាខ្ញុំនេះ បានរួមសុខ-ទុក្ខ កម្សត់កម្រនឹងគ្នាយូរមកហើយ ខ្ញុំមិនងាយបំភ្លេចសេចក្តីកម្សត់នេះបានទេ ហើយមួយទៀត ភរិយាខ្ញុំជាមនុស្សស្រី គ្នាតែងទន់ភ្លន់ជានិច្ច ដូច្នេះហើយបានជាខ្ញុំរកដាច់ចិត្តសម្លាប់មិនកើត" ។ ឮសួរឆ្លើយដូច្នេះ ព្រាហ្មណ៍ ក៏ប្រើឲ្យបុរសនេះត្រឡប់ទៅផ្ទះវិញ ។ ថ្ងៃបន្ទាប់មក ព្រាហ្មណ៍ ឲ្យអមាត្យទៅលបហៅនាងជាភរិយាមកសួរម្តង ។ នាងនោះ មកដល់ភ្លាម, ព្រាហ្មណ៍ ក៏ចាប់សួរថា ៖ "នែនាង" ប្តីនាងជាមនុស្សក្រណាស់ អនាគតនាងក៏ពុំមានសង្ឃឹមអ្វីដែរ, ដូច្នេះ ខ្ញុំស្នើស្ងាត់ៗ ជាមួយនាងថា បើនាងហ៊ានសម្លាប់ប្តីនាង ក្នុងរយៈពេលបីថ្ងៃទៀត ខ្ញុំនឹងលើកនាងជាប្រពន្ធពេញយស ហើយខ្ញុំប្រគល់ដាក់ដៃនាង នូវទ្រព្យសម្បត្តិ មានតម្លៃទាំងអស់ ។ នាងស្រីនោះ នៅស្ងៀមមួយសន្ទុះ ពុំចេញស្តីសោះ, ព្រាហ្មណ៍ព្រឹទ្ធាចារ្យ ក៏អនុញ្ញាតឲ្យនាងយកទៅរេគិតមួយថ្ងៃសិនចុះ ចាំដល់ថ្ងៃស្អែក សឹមមកប្រាប់វិញ ។ នាងស្រីក៏លាចេញទៅ, លុះដល់ថ្ងៃស្អែក ត្រឡប់នាំចម្លើយមកវិញ ។ នាងឆ្លើយជម្រាបព្រាហ្មណ៍ នៅចំពោះព្រះភក្ត្រព្រះមហាក្សត្រថា "ខ្ញុំព្រមធ្វើតាមលោកហើយ ព្រោះខ្ញុំគ្មានសង្ឃឹមលើប្តីខ្ញុំទេ បើរកស៊ីនេសាទត្រីយ៉ាងនេះ" ។

គ្រាន់តែនាងនេះឆ្លើយចប់ភ្លាម, ព្រាហ្មណ៍ព្រឹទ្ធាចារ្យ ក៏ងាកបែរយ៉ាងប្រញាប់ ទៅក្រាបទូលព្រះរាជាមួយរំពេចថា "ក្រាបទូល នេះហើយជាបន្ទាល់ ដែលទូលព្រះបង្គំក្រាបទូលថា ៖ មានចិត្តមុតដូចស្រី" ។

ព្រះមហាក្សត្រ កាលបើព្រះអង្គបានយល់សព្វគ្រប់បន្ទាល់ តាមពាក្យព្រាហ្មណ៍ព្រឹទ្ធាចារ្យរួចហើយ ព្រះអង្គក៏តម្កល់ព្រាហ្មណ៍នេះជាអ្នកប្រាជ្ញធំ ហើយប្រទានពរតាមសេចក្តីប្រាថ្នា ។ ពេលនេះ ព្រាហ្មណ៍ក៏សុំព្រះអង្គអនុញ្ញាតសាងអាស្រមបទ សម្រាប់ពួកព្រាហ្មណ៍ ឲ្យបានស្នាក់ស្នូក្តនៅលើកំពូលភ្នំ ដែលជាប់នឹងព្រះរាជនិវេសនដ្ឋាននេះ ។ ដោយចង់តបស្នង សងគុណព្រាហ្មណ៍នេះផង, ព្រះអង្គ ក៏ទ្រង់ប្រោសព្រះរាជានុញ្ញាតតាមបំណងព្រាហ្មណ៍ ហើយក៏តាំងជាព្រះគ្រូនៃព្រះរាជបុត្រាតរៀងទៅ ។

សេចក្តីអធិប្បាយហូរហែមកនេះ សម្រាប់បញ្ជាក់ឲ្យឃើញនូវប្រវត្តិដើម នៃប្រាសាទបុរាណនៅលើភ្នំជីសូរ គឺមានទាំងបែបប្រវត្តិការណ៍ផង ទាំងបែបរឿងព្រេងផង ។ ប៉ុន្តែ បើយើងផ្ទៀងផ្ទឹម តាមបែបស្រាវជ្រាវប្រវត្តិសាស្ត្រវិញ យើងនិយមយកសិលាចារឹក ធ្វើជាមូលដ្ឋានសំខាន់ជាង ត្បិតសិលាចារឹក ពុំមានអ្នកណាកែប្រែបាន

សូម្បីបន្តិចបន្តួចឡើយ រីឯរឿងព្រេងវិញ រមែងមានវិបត្តិឃ្លៀងឃ្លាតជាធម្មតា ព្រោះអ្នកចាំ នាំមកនិយាយតៗ គ្នា តែងតែមានលើសខ្វះបន្តិចម្នាក់ៗ ជារៀងរាល់គ្នា ។ ដូច្នេះទើបយើងបញ្ជាក់បានថា ប្រាសាទនៅលើភ្នំជីសូរនេះ កសាងឡើងតាំងពីរាជ្យព្រះបាទសុរ្យវរ្ម័នទី ១ រវាង គ. ស. ១០០២ ដល់ ១០៤៩ ដើម្បីឧទ្ទិសថ្វាយទេវរូប តំណាងព្រះសិវៈ ដែលមានសម្មតិនាមមួយ ថា: "គម្តែងជគត ស្រី សុរ្យវរ្ម័ន ទេវៈ" ឬហៅកាត់ខ្លីឲ្យចំថា "ព្រះឥសូរ" ហើយទីនេះក៏មាននាមថា "សុរ្យបរិត" បានន័យថា ភ្នំនៃព្រះបាទសុរ្យវរ្ម័ន